ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរទន្លេសាប

លេខ : ៦២១ អទស

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតក្រុមការងារដាំស្តារព្រៃលិចទឹកឡើងវិញនៅខេត្តទាំង៦ ជុំវិញតំបន់បឹងទន្លេសាប

## រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងជា ប្រធានអាជ្ញាធរទន្លេសាប

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការ បង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការបង្កើតអាជ្ញាធរទន្លេសាប
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣១០/២៥៨ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១០ ស្តីពីការកែសម្រួលមាត្រា៣ មាត្រា៥ មាត្រា៦ មាត្រា៩ មាត្រា១០ និងមាត្រា១២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការបង្កើតអាជ្ញាធរទន្លេសាប
- បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញអនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប
- យោងលិខិតលេខ ៦៩៦ សជណ.កធ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការចាំបាច់របស់អាជ្ញាធរទន្លេសាប

## សម្រេច

**ប្រការ ១.**_

ត្រូវបានបង្កើតក្រុមការងារដាំស្តារព្រៃលិចទឹកឡើងវិញនៅខេត្តទាំង៦ ជុំវិញតំបន់បឹងទន្លេសាប ដែលមានសមាសភាពដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម **សរ គឹមសាន្ត** | អគ្គលេខាធិការ អាជ្ញាធរទន្លេសាប | ប្រធាន |
| ២- | ឯកឧត្តម **ខូច មាស** | អគ្គលេខាធិការរង អាជ្ញាធរទន្លេសាប | អនុប្រធាន |

| | | | | |
|---|---|---|---|---|
| ៣- | លោក | **ទិន ម៉ុនពៅ** | ប្រធាននាយកដ្ឋាន | សមាជិក |
| ៤- | លោក | **ហេង បូរាណា** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៥- | លោក | **ម៉ុន ឧត្តរី** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៦- | លោក | **ខូវ ទេវសុខ** | ប្រធានការិយាល័យ | សមាជិក |
| ៧- | លោក | **សុខ វ៉ាយ៉ុង** | ប្រធានការិយាល័យ | សមាជិក |
| ៨- | លោក | **អ៊ូ ទូច** | ប្រធានការិយាល័យ | សមាជិក |
| ៩- | លោក | **ម៉ម សុធា** | ប្រធានការិយាល័យ | សមាជិក |
| ១០- | លោក | **ឡូញ ណារិទ្ធ** | ប្រធានការិយាល័យ | សមាជិក |
| ១១- | លោក | **ម៉ុក គន្ធារ** | អនុប្រធានការិយាល័យ | សមាជិក |
| ១២- | លោក | **ឃាន ច័ន្ទតារា** | អនុប្រធានការិយាល័យ | សមាជិក |
| ១៣- | លោក | **ជួង សុវណ្ណគិរី** | អនុប្រធានការិយាល័យ | សមាជិក |
| ១៤- | លោក | **ខែត សុវណ្ណឌី** | អនុប្រធានការិយាល័យ | សមាជិក |

**ប្រការ ២.**_

ក្រុមការងារមានភារកិច្ច ដូចខាងក្រោម ៖

- សិក្សា និងប្រមូលចងក្រងព័ត៌មាន ទិន្នន័យពាក់ព័ន្ធនឹងព្រៃលិចទឹកជុំវិញតំបន់បឹងទន្លេសាប
- រៀបចំផែនការ និងផែនទីសម្រាប់ធ្វើការដាំស្តារព្រៃលិចទឹកតំបន់៣ ឡើងវិញ ក្នុងតំបន់ទន្រ្ទាន និងរេចរឹល ស្ថិតក្នុងភូមិសាស្ត្រខេត្តទាំង៦ ជុំវិញតំបន់បឹងទន្លេសាប
- សហការ និងសម្របសម្រួលជាមួយបណ្តាក្រសួង-ស្ថាប័នជំនាញ អង្គការសង្គមស៊ីវិល និងដៃគូពាក់ព័ន្ធក្នុងការដាំស្តារព្រៃលិចទឹកឡើងវិញ ស្ថិតក្នុងភូមិសាស្ត្រខេត្តទាំង៦ ជុំវិញតំបន់បឹងទន្លេសាប
- សម្របសម្រួល និងកៀរគរជំនួយគាំទ្រទាំងផ្នែកបច្ចេកទេស និងថវិកាពីដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធសម្រាប់ធ្វើការដាំស្តារព្រៃលិចទឹកឡើងវិញ ស្ថិតក្នុងភូមិសាស្ត្រខេត្តទាំង៦ ជុំវិញតំបន់បឹងទន្លេសាប
- រៀបចំរបាយការណ៍វឌ្ឍនភាពអនុវត្តការងារជូន ឯកឧត្តមប្រធាន ដើម្បីពិនិត្យ និងផ្តល់អនុសាសន៍ណែនាំ
- បំពេញភារកិច្ចផ្សេងៗទៀតដែល ឯកឧត្តមប្រធានអាជ្ញាធរទន្លេសាប ប្រគល់ជូន។

**ប្រការ ៣.**_

ក្រុមការងារនេះ មានសិទ្ធិប្រើប្រាស់មន្ត្រីក្រោមឱវាទអាជ្ញាធរទន្លេសាប ឱ្យជួយការងារតាមការចាំបាច់។

**ប្រការ ៤.**_

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៥.**_

អនុប្រធាន អគ្គលេខាធិការ អគ្គលេខាធិការរង ទីប្រឹក្សា គ្រប់ប្រធាននាយកដ្ឋានចំណុះឱ្យអគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃពុធ ១២កើត ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០២៥

**រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម**

**និងជា ប្រធានអាជ្ញាធរទន្លេសាប**

ថោ_ជេដ្ឋា

<u>ចម្លងជូន</u> ៖

-ក្រសួងធនធានទឹក និងឧតុនិយម

-ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រី

"ដើម្បីជូនជ្រាប"

-ដូចប្រការ ៥ "ដើម្បីអនុវត្ត"

-ឯកសារ-កាលប្បវត្តិ